Pacific Daily News
PART OF THE USA TODAY NETWORK
http://www.guampdn.com/story/opinion/2016/03/17/khmer-peoples-1970-revolt/81855900/

Khmer people's 1970 revolt

# កុបកម្មប្រជាពលរដ្ឋខ្មែរឆ្នាំ១៩៧០

និពន្ធ ដោយបណ្ឌិត ហ្គាហ្វារ ពាង់ម៉េត ថ្ងៃ ១៨ មីនា ឆ្នាំ ២០១៦
បកប្រែនិងកែសម្រួលដោយ លោក មូលី ធិរិទ្ធ

លោកនាយករដ្ឋមន្ត្រី ហ៊ុនសែន នៅតែនិយាយឥតឈប់ឈរថា ការបំផ្លិចបំផ្លាញអព្យាក្រិត្យភាពរបស់ប្រទេសកម្ពុជា សង្គ្រាមក្នុងស្រុក របបខ្មែរក្រហមប្រល័យពូជសាសន៍ ការទម្លាក់គ្រាប់បែកអាមេរិកាំង បេ-៥២ លើប្រទេសកម្ពុជា ជាលទ្ធផលចេញមកពីការធ្វើរដ្ឋ ប្រហារនៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ ១៩៧០ ពីសំណាក់ លោក លន់នល់ និង ទ្រង់ សិរីមៈតៈ ។ ការនិយាយបែបនេះ គឺបំបិទបំបាំងមិនឱ្យប្រជាពលរដ្ឋខ្មែរដឹងពិតប្រាកដ អំពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន ។

គោលបំណងរបស់លោកហ៊ុនសែនមានច្រើនយ៉ាង៖

- បន្សាបឥទ្ធិពលព្រះវីរៈក្សត្រសីហនុនិងក្រុមរាជានិយម
- ដុតដាលឲ្យមានការមិនទុកចិត្តពីព្រះរាជានិងក្រុមរាជានិយមទៅលើខ្មែរប្រជាធិបតេយ្យដែលមានគំនិតឯករាជ្យ និងបង្កភាពចលាចលគំនុំពិរោធន៍
- ទុកប្រជាពលរដ្ឋខ្មែរឲ្យស្ថិតនៅក្នុងភាពល្ងង់ខ្លៅ ដើម្បីឲ្យខ្លួនអាចនៅកាន់ អំណាចតទៅទៀតបានតាមរបៀបទេវរាជ

លោក ស្រី ភាច (១៩៣៨-២០១២) ដែលជាខ្មែរអ្នកកាន់សីល ជាមន្ត្រីជើងចាស់ម្នាក់ ដែលធ្វើការបំរើឲ្យក្រសួងការបរទេសខ្មែរចំនួន ១៦ ឆ្នាំ ។ នៅក្នុងឆ្នាំ ១៩៦៦ ដល់ឆ្នាំ ១៩៦៨ លោកជានាយការិយាល័យផ្នែកសារព័ត៌មាននិងព័ត៌មាន ។ នៅមុនពេលលោកទទួលមរណៈភាព លោកបានសរសេរ ដោយផ្ទាល់ដៃនូវបទនិពន្ធ ពីរច្បាប់ ចោទប្រកាន់លោកហ៊ុនសែនថា បានកែច្នៃនិយាយកុហកអំពីប្រវត្តិសាស្ត្រខ្មែរ ។ លោកបានប្រគល់បទនិពន្ធទាំងពីរច្បាប់នោះឲ្យមកខ្ញុំ ។ ឈឺនៅលើគ្រែ លោកបានខំរំលឹក ខ្ញុំពីកាប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ថា "វត្ថុជាតុបីដែលគេមិនអាចលាក់បាំងបាននោះគឺ ព្រះអាទិត្យ ព្រះច័ន្ទ និងការពិត" ។

នៅថ្ងៃនេះ ខ្ញុំសរសេរអត្ថបទរំលឹកព្រឹត្តការណ៍ថ្ងៃ១៨មីនាឆ្នាំ១៩៧០ ដោយក្ដីរំភើបក្ដុក ក្ដួលក្នុងចិត្តក្រៃលែង ។

## ការពិសោធន៍ផ្ទាល់របស់លោក ស្រី ភាច

នៅពេលដែលលោកស្រី Jacqueline Kennedy ធ្វើទស្សនៈកិច្ចនៅប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩៦៧ លោក McArthur និងលោក Faas ដែលអ្នកយកព័ត៌មាននៃទីភ្នាក់ងារ ព័ត៌មាន AP ហើយនិងលោក Herndon អ្នកយកព័ត៌មានរបស់ UPI បានលួចគេចខ្លួន ចេញពីទីក្រុងភ្នំពេញធ្វើដំណើរទៅកាន់ជាយដែនកម្ពុជា-វៀតណាម ហើយបានរកឃើញ ទីជំរកមួយចំនួនរបស់កងទ័ពរៀបរយប្រដាប់អាវុធយៀកកុង- វៀតណាមខាងជើង ឬ VC/NVN នៅតំបន់ មេម៉ត់ ខេត្តកំពង់ចាម ចម្ងាយ ៤ ម៉ែលចូលលើទឹកដីខ្មែរ ។ រាជរដ្ឋាភិបាលខ្មែរបានប្រានចោលរបាយការណ៍ទាំងនោះថាមិនពិត ។ លោកស្រីភាចបាន ទទួលភារៈកិច្ចអញ្ជើញគណៈកម្មការត្រួតពិនិត្យអន្តរជាតិ ឬ ICC ធ្វើការស៊ើបអង្កេត ។

ជាទម្លាប់ គេរៀបចំកិច្ចការនានាយ៉ាងឆាប់រហ័ស ។ លោកអភិបាលខេត្តកំពង់ចាម "បានរៀបចំកិច្ចការ" ជាមួយកងទ័ព VC/NVN ឲ្យចាកចេញពីតំបន់ និងកែប្រែទីជំរកទាំង នោះឲ្យទៅជាជំរំហ្វឹកហ្វឺនរបស់ខ្មែរទៅវិញ ។

លោក ស្រីភាច និងមន្ត្រីយោធាខ្មែរពីររូបទៀតបាននាំគណៈប្រតិភូ ICC (ពីប្រទេស ឥណ្ឌៀ កាណាដា និងប៉ូឡូញ) តាមឧទ្ធម្ភាគចក្រឆ្ពោះទៅកាន់ មេម៉ត់។ បន្ទាប់ពីរកមូលដ្ឋានយោធា VC/NVN មិនឃើញ អ្នកអង្កេតការណ៍ជាតិប៉ូឡូញបានអោបលោក ស្រីភាច ហើយសំដែងការកោតសរសើរលោកថា "លោកធ្វើកិច្ចការបានល្អចំណាប់ណាស់"។

នៅក្នុងឧបត្តិហេតុមួយទៀត នៅខេត្តរតនៈគីរីនិងមណ្ឌលគីរី លោក ស្រីភាច បានអង្វរករស្ថានទូត VC/NVN ឲ្យដកកងទ័ពរៀបរយរបស់ខ្លួនចេញឱ្យផុត មុនពេលគណៈប្រតិភូ ICC ទៅដល់ទីនោះ រួចត្រឡប់ចូលមកវិញចុះបន្ទាប់ពីទស្សនៈកិច្ចនោះចប់សព្វគ្រប់ហើយ ។

ស្ថិតនៅក្នុងការភ្ញាក់ផ្អើលមួយ លោក ស្រីភាច បានរាយការជូនចៅហ្វាយនាយរបស់លោក គឺព្រះអង្គម្ចាស់ ភូរីសារ៉ា រដ្ឋមន្ត្រីក្រសួងការបរទេស ដែលមានការព្រួយបារម្ភយ៉ាងក្រៃ លែងនោះដែរ ។ លោក ស្រីភាច បានរាយការថា "អ្នកតំណាងនៃស្ថានទូតទាំងពីរនោះ បានច្រានចោលការអង្វររបស់ខ្ញុំ ហើយបានប្រាប់ខ្ញុំថាប្រសិនបើខ្ញុំនិងគណៈប្រតិភូ ICC ទៅធ្វើទស្សនៈកិច្ចនៅទីនោះ គេនឹងបាញ់មកលើពួកយើងខ្ញុំហើយ" ។

## ការធ្វើឲ្យខូចនាសអព្យាក្រឹតភាពរបស់ស្រុកខ្មែរ

នៅក្នុងឆ្នាំ ១៩៧០ គេនិយមនិយាយរ៉ាយរ៉ាប់អំពីរដ្ឋប្រហារដែលធ្វើឱ្យវិនាសអព្យាក្រិតភាពរបស់ស្រុកខ្មែរ ។ នៅក្នុងឆ្នាំ ១៩៨០ ខ្ញុំបានដាក់បញ្ចូលអត្ថបទពួកកុម្មុនិស្តន៍ចំនួនពីរច្បាប់ក្នុងបណ្តាឯកសារយោងនានាទាំងឡាយទៀត ទៅក្នុងនិក្ខេបបទថ្នាក់បណ្ឌិតរបស់ខ្ញុំនៅ

សាកលមហាវិទ្យាល័យ Michigan និយាយពន្យល់អំពីការបំផ្ទិចបំផ្លាញនៃអព្យាក្រិតភាព នោះ ។

សេចក្តីសង្ខេបសរុបនៃ "ពិធីការ" នៃកិច្ចព្រមព្រៀងសំរាប់ជំនួយយោធាចិនកុម្មុនិស្តន៍ផ្តល់ឲ្យស្រុកខ្មែរ ដែលចុះហត្ថលេខានៅថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៦៥ ដោយលោក ឧត្តមសេនីយ លន់នល់ និងលោកឧត្តមសេនីយចិន Lo Jui-Ching នៃកងទ័ពរំដោះ ប្រជាជនចិន មានចុះផ្សាយនៅក្នុងអត្ថបទរបស់ លោក Chang Hu ក្រោមចំណងជើង "Kung Fei Shen-tou Chien-Pu-Chai Shu Yao" ("ដំណើររឿងត្រូវការចាំបាច់នៃការ ជៀតជ្រៀកកុម្មុនិស្តន៍ចិនក្នុងប្រទេសកម្ពុជា ") នៅក្នុងព្រឹត្តិប័ត្រ *Fei-ching youeh-pao* ("ព្រឹត្តិប័ត្រប្រចាំខែស្តីពីសំនួរកុម្មុនិស្តន៍") ចុះឆ្នាំ១៩៦៩ ៖ "១- ប្រទេសកម្ពុជានឹងអនុញ្ញាត ឲ្យទាហានយួនដើរឆ្លងកាត់និងជ្រកកោននៅក្នុងតំបន់ព្រំប្រទល់ ផ្តល់ដល់ពួកទាហានយួន ទាំងនោះនូវការការពារប្រសិនណាមានការចាំបាច់ ព្រមទាំងអនុញ្ញាតឲ្យទាហានយួន សាងសង់ទីបញ្ជាការផង ។ ២- ប្រទេសកម្ពុជានឹងអនុញ្ញាតឲ្យសម្ភារៈនានាទាំងឡាយ ដឹកមកពីប្រទេសចិនឆ្លងកាត់ទឹកដីរបស់ខ្លួន ហើយដឹកឆ្ពោះទៅឲ្យពួកទាហានយួន" ។

នៅក្នុងសេចក្តីប្រកាសព័តមានរបស់ខ្លួនមួយចុះថ្ងៃទី ៣០ ខែមេសាឆ្នាំ ១៩៧២ នៅទីក្រុងព្យុងយ៉ាង ប្រទេសកូរ៉េខាងជើង ទីភ្នាក់ងារព័តមានមជ្ឈឹមបក្សកូរ៉េគ្រប់គ្រង ដោយរដ្ឋបានរាយការអំពីសេចក្តីសារភាពរបស់សម្តេចសីហនុ ដែលគេផ្សាយថា ព្រះអង្គមានរាជបន្ទូលថា ទ្រង់ "បានសំរេចព្រះហឫទ័យដោយចេតនា" ផ្តល់ជំនួយ "៣ យ៉ាងដែលសំខាន់ជាងគេបំផុត" ទៅឲ្យពួកកុម្មុនិស្តន៍យួនតាំងតែពីឆ្នាំ "១៩៦៣" មកម្ល៉េះ ៖

"១- ការផ្គត់ផ្គង់ខាងអង្ករ ត្រីងៀត និងថ្នាំសង្កូវ ។ល។ ទៅឲ្យពួកទាហានរបស់

(រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង NLF) តាមផ្លូវការ (ស៊ីក) ជាកិច្ចព្រមព្រៀងពាណិជ្ជកម្មមួយជាមួយប្រទេសយួន ដោយមិនគិតរាប់បញ្ចូលនូវអំណោយជាមិត្តភាពនិងភាតរភាពរបស់អង្គការជាតិខ្មែរនៃជំនួយជួយសង្គ្រោះគ្នាទៅវិញទៅមក ដែលមានខ្ញុំ (សីហនុ) ជាប្រធាន ២- ផ្តល់ការអនុញ្ញាត្តិសំងាត់ឲ្យសាងសង់មូលដ្ឋានតូចៗ នៅលើទឹកដីខ្មែរនៅតាមតំបន់ព្រំដែនសំរាប់ពួកទាហាន NLF សំរាកកាយនិងថែទាំមើល ទាហានដែលមានរបួស ៣- ផ្តល់ការចេញចូលដោយសេរីតាមកំពង់ផែព្រះសីហនុ ចំពោះកប៉ាល់នានាទាំងឡាយណាដែលមកពីប្រទេសសង្គមនិយម (ជាពិសេសប្រទេសចិន) ដែលដឹកជញ្ជូនគ្រឿងអាវុធនិងសម្ភារៈយោធាទៅឲ្យ NLF ហើយព្រមទាំងដឹកជញ្ជូនជំនួយ ជាអាវុធនិងសម្ភារៈនានាតាមឡានធំៗរបស់កងខេមរភូមិន្ទពីក្រុងព្រះសីហនុទៅទល់ដែនខ្មែរ-វៀតណាមខាងត្បូង។"

## ស្ថានការណ៍នៅតាមព្រំដែន

នៅក្នុងពេលនោះ អ្នកតំណាងរាស្ត្រខ្មែរបានប្រាប់ទៅសភាជាតិថា មានអ្នកភូមិខ្មែរដែលរស់នៅក្នុងតំបន់ខ្លះដែលគេបោះឆ្នោតត្រូវតែកាន់ "លិខិតបើកផ្លូវ" របស់ VC/NVN ទើបអាច ធ្វើដំណើរទៅមកបាន ។ នៅក្នុងឆ្នាំ ១៩៦៩ លោកនាយករដ្ឋមន្ត្រី លន់នល់ ក៏បានត្រូវគេបាញ់មកលើ នៅឱកាសលោកធ្វើដំណើរត្រួតពិនិត្យនៅតំបន់ទិសឦសាននៃប្រទេសកម្ពុជា ។ កងឯកភាពយោធានានាទាំងឡាយក៏បានរាយការថា គេក៏បានទទួលការពួន ស្ទាក់វាយដែរ ។

នៅដើមខែមីនាឆ្នាំ១៩៧០ កងទ័ពរៀបរយប្រដាប់អាវុធរបស់ VC/NVN បានកាន់កាប់មួយភាគឬពេញទាំងអស់លើផ្ទៃដីចំនួនប្រហែល ៣ ពាន់ ៥ រយគីឡូម៉ែត្រក្រឡានៃទឹកដីខ្មែរ

ដែលលាតសន្ធឹងពី ខេត្តរតនគីរី នៅទិសឦសានទៅ ខេត្តមណ្ឌលគីរី ក្រចេះ កំពង់ចាម ស្វាយរៀង ព្រៃវែង កណ្តាល តាកែវ កំពត ទៅទិសខាងត្បូងរហូតដល់ឈូងសមុទ្រ ។ ពីដំបូងឡើយ នៅថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៧០ មានប្រជាពលរដ្ឋខ្មែរនៅខេត្តស្វាយរៀងបាន ប្រើគ្រឿងអាវុធវាយប្រហារបុគ្គលណាដែលគេសង្ស័យថាបានជួយឧបត្ថម្ភដល់ពួក VC/NVN ។ ភាពចេវចាវក្នុងក្តាំងពេញដោយកំហឹងក៏បានរាលដាលនៅទូទាំងប្រទេស ។ នៅ ថ្ងៃទី ១១ ខែមីនា ក្រុមអ្នកតវ៉ាប្រឆាំងបានបើកការវាយប្រហារទៅលើអាគារនានារបស់ ស្ថាន ទូត VC/NVN នៅក្នុងទីក្រុងភ្នំពេញ ។

យ៉ាងញាប់ដៃជើង លោក លន់នល់ បានផ្ញើទូរលេខចំនួន៧ ទៅថ្វាយសម្តេចសីហនុ ដែល គង់នៅបរទេស ដើម្បីពន្យល់ថ្វាយអំពីព្រឹត្តការណ៍នានាទាំងឡាយ ព្រមទាំងស្នើសុំ បញ្ជូន បេសកជនពីររូបដើម្បីជួបព្រះអង្គ តែដំណើរការនេះពុំបានការឡើយ ។

ពាក្យសំដីខឹងច្រឡោតរបស់ព្រះអង្គសន្យាថានឹងដោះស្រាយជាមួយ "ក្រុមក្បត់មួយក្តាប់" បានផ្សាយលេចឮទៅដល់ទីក្រុងភ្នំពេញ ។ នៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៧០ សភាជាតិ និង ក្រុមប្រឹក្សាព្រះរាជាណាចក្របានជួបជុំគ្នាក្នុងសម័យពេញអង្គមួយ ហើយបានបោះ ឆ្នោត ជាឯកច្ឆន្ទដកហូតមុខងាររបស់សម្តេច នរោត្តម សីហនុ ចេញពីឋានៈជាព្រះ ប្រមុខរដ្ឋខ្មែរ ។ នៅថ្ងៃទី ២៣ ខែមីនា សម្តេច សីហនុ បានស្រែកប្រកូកតាមវិទ្យុឲ្យ មានការបះបោរប្រឆាំង នឹងអាជ្ញាធរកំពុងកាន់អំណាច ។

តាមរយៈកម្មវិធី Power Point ខ្ញុំបានរៀបចំឯកសារមួយបង្ហោះតាមអាសយដ្ឋាន (https://www.youtube.com/watch?v=lR0tRn_mpp0) ផ្តល់ជូននូវប្រវត្តិសាស្ត្រ ខ្មែរជាសង្ខេប អមដោយរូបភាពនិងចំរៀងនានាទាំងឡាយ ។ ខ្ញុំបានដាក់បញ្ចូលរូបថត ខេមរៈជនខ្មែរទាំង ប្រុសទាំងស្រី ដែលបានរួមគ្នាដើរហែរជាក្បួនប្រឆាំងនឹងការឈ្លាន ពានកាន់កាប់ស្រុកខ្មែរពី

សំណាក់ពួក VC/NVN ។ រូបខ្ញុំផ្ទាល់ ខ្ញុំបានដកខ្លួនមួយឆមាស ពីសាកលមហាវិទ្យាល័យ ហើយខ្ញុំក៏បានទៅចូលរួមជាមួយបងប្អូនរួមជាតិខ្មែរ ដែលនៅតស៊ូលើសមរភូមិ ស្អាង និង តាំងគោកផងដែរ ។ ការស្រែកទាមទាររបស់ប្រជាពលរដ្ឋខ្មែរឲ្យមានការកែប្រែផ្លាស់ប្តូរក្នុង ឆ្នាំ ១៩៧០ មិនមែនបានកើតមានឡើងដោយរដ្ឋប្រហារ អ្វីនោះឡើយ ហើយក៏មិនមែនបាន កើតមានឡើងដោយគ្មានហេតុបង្ករៀងរាប់ឆ្នាំយូរ មកហើយនោះដែរ ។

**អំពីអ្នកនិពន្ធ៖**

*លោកបណ្ឌិត ហ្គាហ្វារ ពាងម៉េត អតីតនាយរងអគ្គសេនាធិការនៃកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ បានបង្រៀនវិទ្យាសាស្ត្រនយោបាយនៅសាកលមហាវិទ្យាល័យកោះ Guam អស់រយៈពេល១៣ឆ្នាំ ។ លោកបានចូលនិវត្តិតាំងតែពីឆ្នាំ២០០៤ ហើយបច្ចុប្បន្ននេះលោករស់នៅក្នុងសហរដ្ឋអាមេរិក ។ លោកអ្នកអាចទាក់ទងនឹងលោកបានតាមរយៈសារអេឡិចត្រូនិច*

(e-mail) peangmeth@gmail.com